# ពរជ័យអាពាហ៍ពិពាហ៍ដ៏អស់កល្បជានិច្ច

អែលឌើរ រ៉ែនាត ជី ស្កុត
នៃកូរ៉ុមពួកសាវកដប់ពីរនាក់

*ការផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធមានអត្ថន័យយ៉ាងខ្លាំង នៅពេលជីវិតត្រូវបើកបង្ហាញ ។ វានឹងជួយអ្នកឲ្យខិតកាន់តែជិតគ្នា ហើយរកឃើញក្ដីអំណរ និងសុភមង្គលកាន់តែខ្លាំង ។*

នៅថ្ងៃទី 16 ខែ កក្កដា ឆ្នាំ 1953 ភរិយាជាទីស្រឡាញ់របស់ខ្ញុំ ជេនី និងខ្ញុំបានលុតជង្គង់នៅទីអាសនា ជាគូស្វាមីភរិយាវ័យក្មេងក្នុងព្រះវិហារបរិសុទ្ធ ម៉ានតៃ យូថាហ៍ ។ ប្រធាន ល្វីស អ័រ អាន់ឌើរសិន បានអនុវត្តសិទ្ធិអំណាចនៃការផ្សារភ្ជាប់នោះ ហើយបានប្រកាសដល់យើងថាជាស្វាមី និងភរិយាដែលបានរៀបការសម្រាប់ជីវិតនេះ និងអស់ទាំងភាពអស់កល្បជានិច្ច ។ ខ្ញុំគ្មានអំណាចដើម្បីពិពណ៌នា ឲ្យអស់ពីភាពសុខសាន្ត និងភាពស្ងប់ស្ងាត់ដែលកើតមកពីការអះអាងដែលថា នៅពេលខ្ញុំបន្តរស់នៅឲ្យសក្ដិសម ខ្ញុំនឹងអាចនៅជាមួយនឹងភរិយាជាទីស្រឡាញ់របស់ខ្ញុំ ជេនី និងកូនៗរបស់យើងជារៀងរហូត ដោយសារតែពិធីបរិសុទ្ធដ៏ពិសិដ្ឋនោះធ្វើឡើងដោយសិទ្ធិអំណាចបព្វជិតភាពត្រឹមត្រូវ ក្នុងដំណាក់ព្រះអម្ចាស់ ។

កូនទាំងប្រាំពីរនាក់របស់យើង ត្រូវបានចងភ្ជាប់នឹងយើង ដោយពិធីបរិសុទ្ធដ៏ពិសិដ្ឋនៃព្រះវិហារបរិសុទ្ធ ។ ភរិយាជាទីស្រឡាញ់របស់ខ្ញុំ ជេនី និងកូនពីរនាក់របស់យើងបានទៅនៅឯគតម្ខាងទៀតនៃវាំងននរួចហើយ ។ពួកគេបានផ្ដល់ការលើកទឹកចិត្តដ៏មានអានុភាព ដល់សមាជិកម្នាក់ៗនៃគ្រួសារយើងដែលនៅរស់ឲ្យរស់នៅតាម ដើម្បីយើងនឹងទទួលបានពរជ័យ ដែលបានសន្យាដ៏អស់កល្បជានិច្ចនៅក្នុងព្រះវិហារបរិសុទ្ធជាមួយគ្នា ។

សរសរពន្លឺដ៏សំខាន់ពីរដែលគាំទ្រព្រះវរបិតាសួគ៌ក្នុងផែនការនៃសុភមង្គល គឺអាពាហ៍ពិពាហ៍ និងគ្រួសារ ។ សារៈសំខាន់ដ៏ខ្ពង់ខ្ពស់របស់វា គឺត្រូវបានគូសបញ្ជាក់ ដោយការខិតខំតតឈប់ឈររបស់ សាតាំងក្នុងការបំបែកគ្រួសារ ហើយបំផ្លាញសារៈសំខាន់ នៃពិធីបរិសុទ្ធក្នុងព្រះវិហារបរិសុទ្ធដែលចងភ្ជាប់គ្រួសារជាមួយគ្នា សម្រាប់ភាពអស់កល្បជានិច្ច ។ ការផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធមានអត្ថន័យយ៉ាងខ្លាំង នៅពេលជីវិតត្រូវបើកបង្ហាញ ។ វានឹងជួយអ្នកឲ្យខិតកាន់តែជិតគ្នា ហើយរកឃើញក្ដីអំណរកាន់តែខ្លាំង ព្រមទាំងភាពពោរពេញនៅក្នុងជីវិតរមែងស្លាប់ ។

ពេលមួយខ្ញុំបានរៀនមេរៀនមួយដ៏សំខាន់ពីភរិយារបស់ខ្ញុំ ។ខ្ញុំបានធ្វើដំណើរយ៉ាងឆ្ងាយក្នុងវិជ្ជាជីវៈរបស់ខ្ញុំ ។ ខ្ញុំទៅជិតពីរសប្ដាហ៍ ហើយត្រឡប់មកផ្ទះវិញនៅព្រឹកថ្ងៃសៅរ៍ ។ ខ្ញុំមានពេលបួនម៉ោង មុននឹងខ្ញុំទៅចូលរួមការប្រជុំមួយទៀត ។ ខ្ញុំកត់សំគាល់ឃើញថា ម៉ាស៊ីនបោកគក់តូចរបស់យើងខូច ហើយភរិយារបស់ខ្ញុំ បោកខោអាវដោយដៃ ។ ខ្ញុំចាប់ផ្ដើមជួសជុលម៉ាស៊ីននោះ ។ ជេនី បានដើរមកជិត ហើយសួរថា «រីឆ តើបងកំពុងតែធ្វើអីហ្នឹង ?» ខ្ញុំបានឆ្លើយថា « បងកំពុងតែជួសជុលម៉ាស៊ីនបោកខោអាវ ដើម្បីកុំឲ្យអូនត្រូវបោកខោអាវដោយដៃទៀត » ។ នាងបាននិយាយថា «កុំអី ។ បងទៅលេងជាមួយកូនៗទៅ » ។

ខ្ញុំនិយាយថា « បងអាចលេងជាមួយពួកគេពេលណាក៏បាន ។ តែបងចង់ជួយអូនសិន» ។ រួចហើយនាងនិយាយថា « រីឆាត សូមបងទៅលេងជាមួយកូនៗទៅ » ។ នៅពេលនាងនិយាយមកខ្ញុំដោយអាជ្ញា ខ្ញុំក៏បានធ្វើតាម ។

ខ្ញុំលេងយ៉ាងសប្បាយជាមួយកូនៗរបស់យើង ។ ពួកយើងបានរត់ដេញគ្នា ហើយប្រមៀលខ្លួនទៅលើស្លឹកឈើជ្រុះ ។ ក្រោយមក ខ្ញុំបានទៅប្រជុំ ។ ខ្ញុំប្រហែលជានឹងភ្លេចបទពិសោធន៍នោះ បើវាមិនមែនជាមេរៀន ដែលនាងចង់ឲ្យខ្ញុំរៀន ។

ព្រឹកស្អែកឡើង ប្រហែលជាម៉ោង 4:00 ព្រឹក ខ្ញុំបានភ្ញាក់ឡើង ពេលខ្ញុំបានដឹងថាមានដៃតូចៗឱបករខ្ញុំ ថើបថ្ពាល់ខ្ញុំ ហើយនិយាយខ្សឹបដាក់ត្រចៀកខ្ញុំដែលខ្ញុំមិនអាចបំភ្លេចបានថា ៖ « ប៉ា កូនស្រឡាញ់ប៉ាណាស់ ។ ប៉ាជាមិត្តដ៏ពិសេសរបស់កូន » ។

បើសិនជាអ្នកមានបទពិសោធន៍នេះនៅក្នុងគ្រួសារអ្នក នោះអ្នកមានក្ដីអំណរដ៏វិសេសក្នុងជីវិត ។

បើអ្នកជាយុវជនដែលមានវ័យល្មម ហើយមិនទាន់រៀបការ ចូរកុំចំណាយពេលឥតប្រយោជន៍ ក្នុងការខិតខំដែលឥតបានការ ។សូមចាប់ផ្ដើមជីវិតផ្ដោតទៅលើការរៀបការ ។ ចូរកុំរស់នៅដើម្បីគ្រាន់តែកំដរជីវិតឲ្យសោះ ។ យុវជន ចូរបម្រើបេសកកម្មដោយសក្ដិសម ។ បន្ទាប់មក ចូរដាក់អាទិភាពខ្ពស់បំផុតទៅ

លើការស្វែងរកដៃគូសក្តិសម និងអស់កល្បជានិច្ច ។ នៅពេលអ្នកឃើញថាខ្លួនឯងចាប់អារម្មណ៍លើយុវនារីណាម្នាក់ សូមបង្ហាញនាងថា អ្នកជាមនុស្សពិសេសដែលនាងនឹងចាប់អារម្មណ៍ចង់ស្គាល់កាន់តែច្បាស់ ។ នាំនាងទៅកន្លែងដែលមានអត្ថន័យ ។ បង្ហាញដល់នាងនូវភាពប៉ិនប្រសប់មួយចំនួន ។ បើអ្នកចង់បានភរិយាដ៏អស្ចារ្យម្នាក់នោះ អ្នកត្រូវតែធ្វើឲ្យនាងមើលឃើញថា អ្នកជាបុរសដ៏ល្អ និងជាស្វាមីនាពេលអនាគត ។

បើសិនជាអ្នកជួបមនុស្សម្នាក់ហើយ អ្នកអាចបង្កើតនូវការចែចង់ដ៏ពិសេសអស្ចារ្យមួយ ហើយរៀបការ ហើយមានភាពរីករាយដ៏អស់កល្បជានិច្ច តាមរយៈការស្ថិតនៅក្នុងចំណងនៃភាពសក្តិសមដែលព្រះអម្ចាស់ បានបង្កើតឡើង ។ បើអ្នករៀបការរួចហើយ តើអ្នកស្មោះត្រង់ចំពោះប្តី ឬប្រពន្ធអ្នក ទាំងខាងសតិអារម្មណ៍ ក៏ដូចជាខាងរូបកាយដែរទេ ? តើអ្នកមានភក្តីភាពចំពោះសេចក្តីសញ្ញាអាពាហ៍ពិពាហ៍របស់អ្នក ដោយគ្មានទំនាក់ទំនងសន្ទនានឹងមនុស្សផ្សេងទៀត ដែលអ្នកមិនចង់ឲ្យប្តី ឬប្រពន្ធរបស់អ្នកស្តាប់ឮដែរទេ ? តើអ្នកចិត្តល្អ និងគាំទ្រដល់ប្តី ឬប្រពន្ធ និងកូនៗរបស់អ្នកឬទេ ?

បងប្អូនប្រុស តើអ្នកដឹកនាំសកម្មភាពគ្រួសារ ដូចជាការសិក្សាព្រះគម្ពីរ ការអធិស្ឋានជាគ្រួសារ និងរាត្រីជួបជុំក្រុមគ្រួសារ ឬ តើភរិយារបស់អ្នក បំពេញនៅក្នុងចន្លោះ ដែលអ្នកខ្វះការយកចិត្តទុកដាក់នៅក្នុងគេហដ្ឋានឬទេ ? តើអ្នកប្រាប់ដល់ភរិយារបស់អ្នកញឹកញាប់ថា អ្នកស្រឡាញ់នាងយ៉ាងខ្លាំងឬទេ ? វានឹងធ្វើឲ្យនាងមានសុភមង្គលណាស់ ។ ខ្ញុំបានស្តាប់ឮបុរសៗប្រាប់ខ្ញុំថា « អូ ! នាងដឹងហើយ » ។ អ្នកត្រូវតែប្រាប់នាង ។ ស្ត្រីរីកចម្រើន និងត្រូវបានប្រទានពរតាមរយៈការលួងលោមនោះ ។ សូមបង្ហាញនូវការអរគុណចំពោះអ្វីដែលប្តី ឬប្រពន្ធរបស់អ្នកធ្វើសម្រាប់អ្នក ។ សូមបង្ហាញសេចក្តីស្រឡាញ់ និងការដឹងគុណឲ្យបានញឹកញាប់ ។ នោះនឹងធ្វើឲ្យជីវិតកាន់តែរីករាយខ្លាំងឡើងៗ និងប្រកបដោយគោលបំណង ។ចូរកុំលាក់ការបង្ហាញសេចក្តីស្រឡាញ់ពីធម្មជាតិទាំងនោះ ។ ហើយវាកាន់តែប្រសើរទៀត បើអ្នកឱបនាងពេលអ្នកប្រាប់នាង ។

ខ្ញុំបានរៀនពីភរិយារបស់ខ្ញុំនូវសារៈសំខាន់ អំពីការបង្ហាញទាំងឡាយ ។ ពេលយើងរៀបការដំបូង ជាញឹកញាប់ ខ្ញុំបើកគម្ពីររបស់ខ្ញុំដើម្បីផ្តល់សារលិខិតមួយ ហើយខ្ញុំឃើញក្រដាសសរសេរតូចមួយអំពីក្តីស្រឡាញ់ ការគាំទ្រមកពី ជេនី ស៊កនៅក្នុងទំព័រគម្ពីរ ។ ពេលខ្លះ វាប៉ះនឹងដួងចិត្តខ្លាំងណាស់ ដែលខ្ញុំនិយាយមិនរួច ។ ក្រដាសសរសេរដ៏មានតម្លៃមកពីភរិយាជាទីស្រឡាញ់ទាំងនោះ នៅតែបន្តធ្វើជារតនៈសម្បត្តិដែលមិនអាចកាត់ថ្លៃបាននៃការលួងលោមចិត្ត និងការបំផុសគំនិត ។

ខ្ញុំបានចាប់ផ្តើមធ្វើដូចគ្នាចំពោះនាង ដោយមិនដឹងថាវាមានន័យយ៉ាងខ្លាំងចំពោះនាងសោះ ។ ខ្ញុំចាំថា ក្នុងឆ្នាំមួយ យើងគ្មានធនធាន ដើម្បីខ្ញុំអាចផ្តល់ឲ្យនាងក្នុងថ្ងៃនៃក្តីស្រឡាញ់ទេ ដូច្នេះខ្ញុំបានសម្រេចចិត្តគូរគំនូរប្រើថ្នាំពណ៌លាយទឹក នៅលើទូទឹកកក ។ ខ្ញុំខំដោយអស់ពីសមត្ថភាព ខ្ញុំបានធ្វើកំហុសតែមួយប៉ុណ្ណោះ ។ កំហុសនោះគឺគំនូររលោង មិនមែនពីថ្នាំពណ៌លាយទឹកទេ ។ នាងមិនឲ្យខ្ញុំលុបគំនូរនោះចោលទេ ។

ខ្ញុំចាំបានថាថ្ងៃមួយ ខ្ញុំបានយកក្រដាសមូលៗតូចៗ ដែលបានមកពីការចោះរន្ធនៅលើក្រដាស ហើយខ្ញុំសរសេរពីលេខ 1 ដល់លេខ 100 ។ នៅខ្នងក្រដាសនីមួយៗ ខ្ញុំបានសរសេរសារមួយឲ្យនាង ដោយពាក្យមួយក្នុងក្រដាសមួយមូលតូចៗនោះ ។ បន្ទាប់មក ខ្ញុំប្រមូលវាឡើងដាក់ក្នុងស្រោមសំបុត្រមួយ ។ ខ្ញុំគិតថានាងនឹងអស់សំណើចខ្លាំង ។

នៅពេលនាងស្លាប់ទៅ ខ្ញុំរកឃើញរបស់សម្ងាត់របស់នាងថានាងមានអំណរគុណខ្លាំងណាស់ចំពោះសារលិខិតសាមញ្ញៗដែលយើងបានចែកជាមួយគ្នា ។ ខ្ញុំកត់សំគាល់ឃើញថា នាងបានបិទក្រដាសតូចៗទាំងនោះដោយយកចិត្តទុកដាក់នៅលើក្រដាសធំមួយ ។ នាងមិនត្រឹមតែរក្សាសាររបស់ខ្ញុំចំពោះនាងប៉ុណ្ណោះទេ ប៉ុន្តែនាងបានការពារវាដោយដាក់នៅក្នុងថង់ប្លាស្ទិក ដូចជារតនៈសម្បត្តិដ៏មានតម្លៃមួយ ។ នោះគឺជាវត្ថុតែមួយដែលនាងមិនបានដាក់ជាមួយនឹងរបស់ផ្សេងទៀត ។វានៅតែបិទនៅក្នុងនាឡិកាកញ្ចក់ក្នុងចង្ក្រានបាយរបស់យើង ។ វាសរសេរថា « ជេនី ជាពេលដែលបងប្រាប់អូនថា បងស្រឡាញ់អូន » ។ វានៅតែជាការរំឭកដល់ខ្ញុំ អំពីបុត្រីដ៏ពិសេសរបស់ព្រះវរបិតានៅស្ថានសួគ៌ ។

នៅពេលខ្ញុំគិតអំពីជីវិតរបស់យើងពេលនៅជាមួយគ្នា ខ្ញុំដឹងថា យើងមានពរជ័យណាស់ ។ យើងគ្មានការឈ្លោះប្រកែកគ្នានៅក្នុងផ្ទះ ឬពាក្យមិនពីរោះរវាងពួកយើងទេ ។ ឥឡូវ ខ្ញុំដឹងថា ពរជ័យនោះបានមកពីនាង ។ វាជាលទ្ធផលមកពីការស្ម័គ្រចិត្តរបស់នាងដើម្បីផ្តល់ឲ្យ ចែកចាយ និងមិនដែលគិតពីខ្លួនឯង ។ ក្រោយមក នៅក្នុងជីវិតរបស់ពួកយើងជាមួយគ្នាខ្ញុំបានព្យាយាមដើម្បីធ្វើតាមគំរូរបស់នាង ។ ខ្ញុំឲ្យយោបល់ថា ក្នុងនាមជាស្វាមី និងភរិយា អ្នកគួរធ្វើដូចគ្នានេះក្នុងគេហដ្ឋានរបស់អ្នក ។

សេចក្ដីស្រឡាញ់ដ៏បរិសុទ្ធ គឺមិនអាចប្រៀបផ្ទឹមបានទេ វាជាអំណាចដ៏វិសេសសម្រាប់សេចក្ដីល្អ ។ ក្ដីស្រឡាញ់ដ៏សុចរិត គឺជាគ្រឹះនៃអាពាហ៍ពិពាហ៍ដ៏មានជោគជ័យ ។ វាគឺជាមូលហេតុចម្បងនាំឲ្យកូនៗរីករាយ និងអភិវឌ្ឍបានល្អ ។ តើនរណាអាចវាស់វែងឲ្យត្រឹមត្រូវនូវឥទ្ធិពលសុចរិតនៃក្ដីស្រឡាញ់របស់ម្ដាយបាន ? តើផលនៃការស៊ូទ្រាំអ្វីខ្លះ ដែលកើតចេញពីគ្រាប់ពូជនៃសេចក្ដីពិត ដែលម្ដាយម្នាក់ បានបណ្ដុះដោយយកចិត្តទុកដាក់ និងមើលថាំដោយក្ដីស្រឡាញ់ នៅក្នុងដីដ៏មានជីវជាតិ នៃគំនិត និងដួងចិត្តរបស់កូនម្នាក់នោះ ? ក្នុងនាមជាម្ដាយ អ្នកត្រូវបានប្រទានឲ្យនូវសភាវគតិពីព្រះ ដើម្បីជួយអ្នកយល់អំពីទេពកោសល្យ និងសមត្ថភាពពិសេសរបស់កូន ។ អ្នកអាចចិញ្ចឹមបីបាច់ ពង្រឹង និងបណ្ដាលឲ្យលក្ខណៈទាំងនោះរីកលូតលាស់ជាមួយនឹងស្វាមីរបស់អ្នក ។

អាពាហ៍ពិពាហ៍គឺជារង្វាន់ដ៏អស្ចារ្យ ។ អាពាហ៍ពិពាហ៍អស្ចារ្យណាស់ ។ នៅពេលអ្នកចាប់ផ្ដើមគិតដូចគ្នា ហើយមានគំនិត និងអារម្មណ៍ដូចគ្នា ។អ្នកមានគ្រាដែលអ្នកសប្បាយរីករាយបំផុត គ្រានៃការសោកល្បង និង គ្រានៃឧបសគ្គ ប៉ុន្តែព្រះអម្ចាស់ដឹកនាំអ្នកឆ្លងកាត់បទពិសោធន៍នៃការរីកចម្រើនទាំងអស់នោះជាមួយគ្នា ។

មានយប់មួយ កូនប្រុសតូចរបស់យើងឈ្មោះ រីឆាត ដែលមានបញ្ហាបេះដូងបានភ្ញាក់ឡើងយំ ។ យើងទាំងពីរនាក់បានស្ដាប់ឮ ។ ជាធម្មតា ភរិយារបស់ខ្ញុំក្រោកឡើងទៅមើលកូនយំជានិច្ច ប៉ុន្តែពេលនេះ ខ្ញុំនិយាយថា « ទុកឲ្យបងទៅមើលកូនវិញ » ។

ដោយសារតែបញ្ហារបស់គាត់ នៅពេលគាត់យំ បេះដូងតូចរបស់គាត់នឹងលោតយ៉ាងញាប់ ។ គាត់នឹងក្អួតប្រឡាក់កម្រាលគ្រែ ។ យប់នោះ ខ្ញុំបានបីគាត់យ៉ាងណែន ព្យាយាមដើម្បីរម្ងាប់បេះដូងដែលលោតយ៉ាងខ្លាំងរបស់គាត់ កុំឲ្យគាត់យំ ពេលខ្ញុំផ្លាស់សំលៀកបំពាក់របស់គាត់ និងដាក់កម្រាលគ្រែថ្មី ។ ខ្ញុំបានបីគាត់រហូតដល់គាត់គេងលក់ ។ ខ្ញុំមិនដឹងពេលនោះថា នៅប៉ុន្មានខែក្រោយ គាត់នឹងស្លាប់ទេ ។ ខ្ញុំចងចាំជានិច្ចនៅគ្រាដែលខ្ញុំបីគាត់ក្នុងដៃ នៅយប់កណ្ដាលអាធ្រាត្រនោះ ។

ខ្ញុំចាំយ៉ាងច្បាស់នូវថ្ងៃដែលគាត់បានស្លាប់ ។ នៅពេល ជេនី និងខ្ញុំបើកឡានមកពីមន្ទីរពេទ្យវិញ យើងបានឈប់នៅកៀនផ្លូវ ។ ខ្ញុំបានឱបនាងក្នុងរង្វង់ដៃ ។ យើងបានយំបន្តិចបន្តួច ប៉ុន្តែយើងបានដឹងថា យើងនឹងរស់នៅជាមួយនឹងគាត់ម្ដងទៀតនៅជីវិតក្រោយ ដោយសារតែសេចក្ដីសញ្ញា ដែលយើងបានធ្វើនៅក្នុងព្រះវិហារបរិសុទ្ធ ។ នោះធ្វើឲ្យយើងអាចទទួលយកការបាត់បង់គាត់បានងាយស្រួលបន្តិច ។

សណ្ដានចិត្តរបស់ ជេនី បានបង្រៀនខ្ញុំនូវរឿងដ៏មានតម្លៃជាច្រើន ។ ខ្ញុំនៅក្មេងខ្ចីណាស់ ហើយនាងមានការលត់ដំខ្លួន និងខាងវិញ្ញាណខ្ពស់ ។ អាពាហ៍ពិពាហ៍ផ្ដល់ជាទីតាំងពិសេស សម្រាប់ការយកឈ្នះរាល់ទំនោរអាត្មានិយម ឬការគិតតែពីខ្លួនឯង ។ ខ្ញុំគិតអំពីមូលហេតុមួយ ដែលយើងត្រូវបានទូន្មានឲ្យរៀបការពីក្មេង គឺដើម្បីចៀសវាងពីការអភិវឌ្ឍន៍លក្ខណៈចរិតមិនសមរម្យ ដែលពិបាកផ្លាស់ប្ដូរ ។

ខ្ញុំសោកស្ដាយចំពោះបុរសដែលមិនទាន់ធ្វើការសម្រេចចិត្ត ដើម្បីស្វែងរកដៃគូអស់កល្បជានិច្ច ហើយដួងចិត្តរបស់ខ្ញុំយំចំពោះស្ត្រី ដែលគ្មានឱកាសរៀបការ ។ អ្នករាល់គ្នាមួយចំនួនមានអារម្មណ៍ឯកោ និងគ្មានតម្លៃ ហើយមិនអាចមើលឃើញលទ្ធភាពសម្រាប់ខ្លួន ដើម្បីមានពរជ័យនៃ អាពាហ៍ -ពិពាហ៍ និងកូនៗ ឬគ្រួសារផ្ទាល់ខ្លួនបានឡើយ ។ អ្វីៗគ្រប់យ៉ាង អាចកើតឡើងបាន ចំពោះព្រះអម្ចាស់ ហើយទ្រង់រក្សាការសន្យា ដែលទ្រង់បានបំផុសគំនិតដល់ពួកព្យាការីរបស់ទ្រង់ ឲ្យប្រកាស ។ ភាពអស់កល្បជានិច្ច គឺជាពេលដ៏យូរអង្វែងមួយ ។ ចូរមានជំនឿទៅលើការសន្យាទាំងនោះ ហើយរស់នៅដោយសក្តិសមដើម្បីទុកពេលឲ្យទ្រង់ នោះព្រះអម្ចាស់អាចធ្វើឲ្យវាកើតឡើង មកក្នុងជីវិតរបស់អ្នក ។ ប្រាកដណាស់ អ្នកនឹងទទួលគ្រប់ពរជ័យដែលបានសន្យា ដែលអ្នកសក្តិសមនឹងទទួល ។

សូមអត់ទោសដល់ខ្ញុំក្នុងការនិយាយអំពីភរិយាដ៏អស្ចារ្យរបស់ខ្ញុំ ជេនី ។ ប៉ុន្តែយើងជាគ្រួសារដ៏អស់កល្បជានិច្ច ។ នាងតែងតែរីករាយ ប្រកបដោយអំណរគុណ ហើយភាគច្រើនកើតចេញមកពីការបម្រើដល់អ្នកដទៃ ។ សូម្បីតែពេលនាងឈឺធ្ងន់ ក៏នៅក្នុងការអធិស្ឋានពេលព្រឹករបស់នាង នាងបានសុំដល់ព្រះវរបិតាសួគ៌ ដើម្បីដឹកនាំនាងទៅជួបនឹងនរណាម្នាក់ ដែលនាងអាចជួយបាន ។ ការអធិស្ឋានដោយស្មោះនោះ ត្រូវបានឆ្លើយតបម្ដងហើយម្ដងទៀត ។ បន្ទុករបស់មនុស្សជាច្រើនត្រូវបានសម្រាល ជីវិតរបស់ពួកគេត្រូវបានភ្លឺថ្លាឡើង ។ នាងត្រូវបានប្រទានពរជាបន្តបន្ទាប់ សម្រាប់ធ្វើជាឧបករណ៍ ដែលបានដឹកនាំដោយព្រះអម្ចាស់ ។

ខ្ញុំដឹងថាអ្វីជាក្ដីស្រឡាញ់ចំពោះបុត្រីរបស់ព្រះវរបិតាសួគ៌ា ដែលពេញដោយព្រះគុណ និងការលះបង់ ដែលបានរស់នៅដ៏មានកិត្តិយសពេញដោយភាពទន់ភ្លន់ នៃភាពជាស្ត្រីសុចរិតរបស់ខ្លួន ។ នៅក្នុងពេលអនាគត ខ្ញុំមានទំនុកចិត្តថា ពេលខ្ញុំជួបនាងនៅជីវិតក្រោយម្ដងទៀត យើងនឹងទទួលស្គាល់ថាយើងបានស្រឡាញ់គ្នាកាន់តែខ្លាំង ។ យើងនឹងដឹងគុណ ចំពោះគ្នាទៅវិញទៅមកកាន់តែច្រើន ដែលបានចំណាយពេលនេះ នៅបែកពីគ្នា ដោយរាំងនននៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។